ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង
# ស្តីពី
# ការរស់នៅតាមគន្លងប្រក្រតីភាពថ្មី
# ក្នុងបរិបទនៃជំងឺកូវីដ-១៩


រៀបចំដោយ៖

អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល
និងទំនាក់ទំនងសាធារណៈនៃគណៈកម្មការអន្តរក្រសួង
ប្រយុទ្ធនឹងជំងឺកូវីដ-១៩

# មាតិកា

១. សេចក្តីផ្តើម......6
១.១ បរិបទហានិភ័យ......7
១.២ បញ្ហាប្រឈម......9
២. គោលដៅយុទ្ធសាស្ត្រ......11
៣. វិធីសាស្ត្រអនុវត្តយុទ្ធសាស្ត្រសំខាន់ៗ......13
៣.១ យុទ្ធសាស្ត្រនៃបទអន្តរាគមន៍សំខាន់ៗ......14
៤. ដៃគូចូលរួមអនុវត្ត......16
៥. សារអប់រំ និងវិធីសាស្ត្រផ្សព្វផ្សាយ......18
៥.១ វិធានការសុខភាពសាធារណៈនិងសង្គម......18
៥.២ សារអប់រំពីការចាក់វ៉ាក់សាំង......19
៦. ផែនកាប្រាស្រ័យទាក់ទង......21
៧. ឧបសម្ព័ន្ធ......25

# សេចក្ដីសង្ខេប

# សេចក្តីសង្ខេប

## ៣ការពារ







## ៣កុំ









ផែនការយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ត្រូវបានបង្កើតឡើងដើម្បីឱ្យមានភាពស៊ីគ្នាជាមួយផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ "ការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩" ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាកំពុងឈានទៅកាន់ដំណាក់កាលថ្មី ដែលប្រជាជនរស់នៅជាមួយមេរោគ និងបន្តអនុវត្តដោយខ្លួនឯងនូវរាល់វិធានការបង្ការផ្សេងៗ និងការចាក់វ៉ាក់សាំង ។

មនុស្សគ្រប់រូបត្រូវតែគោរពតាមវិធានការសុខភាពសាធារណៈនិងសង្គម និងការចាក់វ៉ាក់ ជាពិសេសអ្នកដែលងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ ដូចជាស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និងប្រជាជនដែលមិនទាន់ទទួលបាន ។

ផែនការប្រាស្រ័យទាក់ទងនេះ កំណត់នូវបញ្ហាសំខាន់ៗមួយចំនួនដូចជាកំណត់គោលដៅច្បាស់លាស់ជាមួយនឹងវិធីសាស្ត្រនិងបទអន្តរាគមន៍ ដែលអាចឱ្យដៃគូប្រើប្រាស់នូវសារសំខាន់ៗដែលពាក់ព័ន្ធ ដើម្បីដោះស្រាយជាមួយប្រជាជនគោលដៅផ្សេងៗដែលជួបហានិភ័យ ។ ដើម្បីសម្រេចបាននូវគោលបំណងដ៏ធំធេងនៃផែនការនេះ ក្នុងការឆ្លើយតបទៅនឹងគោលដៅរួមនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់ការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩, អ្នកពាក់ព័ន្ធនិងដៃគូអនុវត្តទាំងអស់ គួរតែជ្រើសរើសដោយប្រុងប្រយ័ត្ននូវវិធានការដែលសមស្រប និងសារគន្លឹះសំខាន់ៗសម្រាប់ប្រជាជនក្រុមគោលដៅដែលជាក់លាក់ ។

បន្ថែមលើសពីនេះ វាមានសារៈសំខាន់ណាស់ដែលការកសាងសមត្ថភាពដល់អ្នកពាក់ព័ន្ធនិងដៃគូអនុវត្តនានា រួមទាំងអ្នកស្ម័គ្រចិត្ត ត្រូវយកមកពិចារណាលើជំនាញ និងតើនរណាជាមនុស្សដ៏ត្រឹមត្រូវសម្រាប់កិច្ចការពិសេសនេះ ។ លើសពីនេះ ឧបករណ៍និងសម្ភារផ្សេងទៀតគួរត្រូវបានពិនិត្យកែសម្រួលសម្រាប់ការផលិតឡើងវិញយ៉ាងហ្មត់ចត់ ឬការបង្កើតសម្ភារថ្មីអាស្រ័យលើតម្រូវការជាក់ស្តែង ។

# សេចក្តីផ្តើម

# ១. សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការចង្អុលបង្ហាញដោយផ្ទាល់ប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់និងឈ្លាសវៃរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា** បានគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពនិងបានប្រកាសដំណើរការប្រទេសឡើងវិញលើគ្រប់វិស័យតាមប្រក្រតីភាពគន្លងថ្មី និងបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ។

ផែនការយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនេះ គឺរៀបចំឡើងស្របទៅនឹង *"យុទ្ធសាស្ត្រស្ដីពីការរស់នៅតាមគន្លងប្រក្រតីថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ "* ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាដើម្បីធានានូវដំណើរការរស់នៅក្នុងប្រក្រតីភាពគន្លងថ្មីប្រកបដោយនិរន្តរភាព ជាមួយនឹងការពិចារណាអំពីតម្រូវការឆ្លើយតបចំពោះវិធានការនានារបស់ការិយាល័យអង្គការសុខភាពពិភពលោកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកចំពោះការគ្រប់គ្រងជំងឺកូវីដ-១៩ នៅថ្ងៃអនាគត។

ដូចប្រទេសនានាលើពិភពលោកដែរ ប្រទេសកម្ពុជាកំពុងតែប្ដូរទៅរកដំណាក់កាលថ្មីនៃការវិវត្តនៃជំងឺកូវីដ-១៩ ដូច្នេះការប្រាស្រ័យទាក់ទងមួយដែលមានអំណះអំណាងនិងមានការកំណត់ក្រុមគោលដៅចំពោះអ្នកទទួលសារអប់រំ និងដោយមានប្រសិទ្ធភាព ជាពិសេស មានការចូលរួមរបស់សហគមន៍ គឺត្រូវប្រាកដថា ប្រជាពលរដ្ឋយល់ថាជំងឺរាតត្បាតនេះមិនទាន់បានបញ្ចប់នៅឡើយទេ ដូច្នេះប្រជាពលរដ្ឋគ្រប់រូបត្រូវតែមានការប្រុងប្រយ័ត្នជានិច្ច។ នេះមានន័យថា ធ្វើឲ្យប្រសើរឡើងចំពោះការអនុវត្តវិធានការសុខភាពសាធារណៈ និងការលើកទឹកចិត្តប្រជាពលរដ្ឋឲ្យមកចាក់វ៉ាក់សាំងនៅពេលដែលវេនរបស់ពួកគាត់។

គោលដៅទី១ នៃយុទ្ធសាស្ត្រជាតិ គឺដើម្បីការពារអាយុជីវិតនិងសុវត្ថិភាពក្នុងការរស់នៅ និងក្នុងការចូលរួមរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសកម្មភាពសង្គមសេដ្ឋកិច្ច។ នៅក្នុងយុទ្ធសាស្ត្រទី៣ ***រក្សាការប្រាស្រ័យទាក់ទងហានិភ័យ និងទំនាក់ទំនងសាធារណៈប្រកបដោយប្រសិទ្ធភាព និងទាន់ពេល ជាពិសេសក្នុងករណីមានការឆ្លងរាលដាលក្នុងទ្រង់ទ្រាយធំ*** ដើម្បីគាំទ្រការសម្រេចបានគោលដៅទី២នៃយុទ្ធសាស្ត្រពង្រឹងសមត្ថភាពស្នូលនៃប្រព័ន្ធសុខាភិបាល ដើម្បីបង្ការនិងគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ ផងនិងផ្ដល់សេវាសុខាភិបាលជាសារវ័ន្តជាប្រចាំផង និងកាត់បន្ថយផលប៉ះពាល់សុខភាព សង្គម និងសេដ្ឋកិច្ច។

ដើម្បីអនុវត្តនិងឈានទៅរកការសម្រេចបានគោលបំណងនៃយុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រប្រាស្រ័យទាក់មានគឺសារៈសំខាន់។ ចំណុចសំខាន់នៃផែនការយុទ្ធសាស្ត្រនេះការពង្រឹងការប្រាស្រ័យទាក់ទងនិងសារអប់រំអំពីសារៈសំខាន់ចំពោះការបន្តការអនុវត្ត ៣ ការពារ និង ៣ កុំ និងវិធានការសុខាភិបាលផ្សេងៗទៀត ដោយមានការពន្យល់ដល់ប្រជាពលរដ្ឋ គឺជាមធ្យោបាយមួយដើម្បីឲ្យប្រទេសកម្ពុជានៅតែអាច

បន្តបើកដំណើរការសង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ហើយសហគមន៍នៅតែបន្តការងារប្រចាំថ្ងៃរបស់គេ ប៉ុន្តែត្រូវទទួលស្គាល់អំពីហានិភ័យ ដែលការផ្ទុះឡើងវិញនៃជំងឺកូវីដ-១៩នេះអាចកើតមានឡើងវិញនៅពេលអនាគត ហើយការព្រួយបារម្ភណ៍ និងការភ័យខ្លាចរបស់ប្រជាជនចំពោះជំងឺនេះក៏អាចកើតមានសាជាថ្មី ដូច្នេះបុគ្គលនិងសហគមន៍ត្រូវ បន្តការអនុវត្តវិធានការយ៉ាងខ្ជាប់ខ្ជួន ។ ការប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយដែលមានលក្ខណៈសមស្រប និងការបន្តការកែសម្រួលសារអប់រំ ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការ និងភាពចាំបាច់របស់ប្រជាពលរដ្ឋជាពិសេសប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត និងជួយរក្សាបានការលើកកម្ពស់ការយល់ដឹង និងពង្រឹងភាពជឿជាក់លើសកម្មភាពរបស់រដ្ឋាភិបាល និងជួយគ្រប់គ្រងការផ្តល់ព័ត៌មានមិនពិត និងពាក្យចចាមអារាម តាមរយៈការពិភាក្សារបស់សហគមន៍ និងការប្រាស្រ័យទាក់ទងដែលមានការឆ្លើយតប។

បទពិសោធន៍ដែលទទួលបានពីការអនុវត្តសកម្មភាព អំពីការចូលរួមរបស់សហគមន៍ រួមទាំងការគាំទ្ររបស់អង្គការសុខភាពពិភពលោកលើការពង្រឹងការចូលរួមរបស់សហគមន៍នៅក្នុងខេត្តអាទិភាពទាំង៩ បានជួយចង្អុលបង្ហាញដល់ បុគ្គលិកមន្ទីរសុខាភិបាលខេត្ត/ស្រុកប្រត្តិបត្តិ និងអជ្ញាធរមូលដ្ឋាន ដើម្បីដឹកនាំសកម្មភាពអន្តរាគមន៍អំពីការចូលរួមរបស់សហគមន៍នៅថ្នាក់មូលដ្ឋាន។ ជាងនេះទៅទៀត វគ្គបណ្តុះបណ្តាលត្រូវបានរៀបផែនការឡើង ដើម្បីណែនាំដល់ប្រធានភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ អ្នកដឹកនាំសាសនា គ្រូបង្រៀនជាដើម ដើម្បីបង្កើនការយល់ដឹងអំពីតួនាទីនិងការទទួលខុសត្រូវរបស់ពួកគេ ក្នុងការអនុវត្តសកម្មភាពស្តីពីការចូលរួមរបស់សហគមន៍ឲ្យមានប្រសិទ្ធភាពនិងជំរុញឲ្យសហគមន៍ចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

## ១.១ បរិបទហានិភ័យ

ជំងឺកូវីដ-១៩ មានការផ្ទុះឡើងនៅជុំវិញពិភពលោក និងនៅក្នុងតំបន់ និងសហគមន៍នៅតែមានហានិភ័យនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដោយសារតែផ្នត់គំនិត និងជំនឿនៅក្នុងសហគមន៍មូលដ្ឋាន កត្តាសង្គម និងសកម្មភាពប្រកបរបចិញ្ចឹមជីវិតប្រចាំថ្ងៃ។ នៅពេលដែលព្រះរាជាណាចក្រកម្ពុជាប្រកាសបើកប្រទេសឡើងវិញ ហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ នៅតែមានដោយសារតែការមិនបានអនុវត្តវិធានការការពារ និងគោលការណ៍ណែនាំផ្សេងៗ។ បើទោះជាការសិក្សាស្រាវជ្រាវមួយដែលបានធ្វើឡើងដោយការិយាល័យអង្គការសុខភាពពិភពលោកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក បានរកឃើញថា ចំណេះដឹងរបស់ប្រជាពលរដ្ឋមានការកើនឡើងអំពីវិធានការសុខភាពសាធារណៈនិងសង្គម រហូតដល់៩៥% នៃចំនួនអ្នកឆ្លើយ ដោយប្រជាពលរដ្ឋបានឲ្យដឹងថា ពួកគាត់បានលាងដៃជាមួយសាប៊ូ ប្រើប្រាស់អាកុលសម្រាប់សម្អាតដៃ និងពាក់ម៉ាស់ ក៏ដូចជាការបង្ហាញពីភាពជឿជាក់ និងការទទួលយកការចាក់វ៉ាក់សាំងដែលមានចំនួនប្រមាណ៩៥%នៃអ្នកឆ្លើយ ក្នុងនោះពួកគាត់បានឲ្យដឹងថា ពួកគាត់បានជំរុញសមាជិកគ្រួសារ

របស់គាត់ទៅចាក់វ៉ាក់សាំងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ វាមានការធ្លាក់ចុះចំពោះវិធានការសុខភាពសារណៈ និងសង្គម ដោយប្រជាពលរដ្ឋមិនបានអនុវត្ត ជាពិសេសនៅពេលដែលសង្គមកម្ពុជាបានបើកប្រទេសឡើងវិញ។

នៅក្នុងប្រទេសកម្ពុជា យោងតាមលទ្ធផលអង្កេតជុំទីបី ស្តីពីផ្នត់គំនិត និងការប្រព្រឹត្តរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ដោយផ្តោតលើវិធានការសុខភាពសាធារណៈនិងសង្គម ដែលបានធ្វើឡើងនៅក្នុងខែកញ្ញាឆ្នាំ២០២១ ដោយក្រុមហ៊ុនស្រាវជ្រាវទីផ្សារឯកជនមួយឈ្មោះ (IPSOS) ដែលថ្មីៗបានធ្វើការស្រាវជ្រាវដើម្បីស្វែងយល់ពីចំណេះដឹង ផ្នត់គំនិត និងជំនឿរបស់ប្រជាពលរដ្ឋជុំវិញជំងឺកូវីដ-១៩ ដោយមានការផ្តល់ថវិកាពីអង្គការសុខភាពពិភពលោក បានបង្ហាញថា **"ការព្រួយបារម្ភណ៍"** របស់ប្រជាពលរដ្ឋមានការកើនឡើងអំពីការមិនទទួលបានសេវាកម្មសុខភាព (ប្រមាណ ២៣%នៃអ្នកឆ្លើយ) ហើយប្រជាជនដែលមិនមែនជាអ្នករស់នៅតាមទីប្រជុំជនក៏មិនបានទទួលព័ត៌មានគ្រប់គ្រាន់។

ការអង្កេតនេះក៏បានបង្ហាញពីការកើនឡើងនៃការធ្លាក់ចុះចំពោះផ្នត់គំនិតដែលមានហានិភ័យ ជាពិសេសក្នុងចំណោមក្រុមប្រជាពលរដ្ឋដែលមានអាយុចន្លោះ៣៥–៥៤ឆ្នាំ (៨៣% នៃអ្នកឆ្លើយ)។ សំខាន់បំផុតនោះ គឺការធ្លាក់ចុះចំពោះវិធានការសុខភាពសាធារណៈនិងសង្គមនៅក្នុងអំឡុងពេលនៃការបើកប្រទេសឡើងវិញដែលនាំឲ្យមានការកើនឡើងចំពោះហានិភ័យនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសក្នុងចំណោមក្រុមប្រជាជនដែលងាយរងគ្រោះ រួមទាំងប្រជាជនដែលមិនទាន់បានចាក់វ៉ាក់សាំង និងមនុស្សដែលមានប្រព័ន្ធភាពស៊ាំនៃថ្នាំមិនដំណើរការ (immunocompromised) និងអ្នកដែលមិនបានទទួលព័ត៌មានអំពីរោគសញ្ញា និងហានិភ័យនៃជំងឺកូវីដ-១៩ និងវិធានការការពារជំងឺនៅថ្នាក់មូលដ្ឋាន និងសហគមន៍ជនបទដាច់ស្រយាល។



## ១.២ បញ្ហាប្រឈម

- ប្រជាពលរដ្ឋកម្ពុជាមានការព្រួយបារម្ភណ៍ច្រើនចំពោះការមិនបានទទួលសេវាសុខាភិបាល ដែលមានការកើនឡើងប្រមាន ២៣% ប្រៀបធៀបនឹងការអង្កេតលើកទី២ ហើយប្រជាពលរដ្ឋដែលមិនរស់នៅទីប្រជុំជនមិនទាន់បានទទួលព័ត៌មានគ្រប់គ្រាន់។
- ប្រជាពលរដ្ឋកម្ពុជាមិនបានអនុវត្ត ឬអនុវត្តមិនបានពេញលេញចំពោះវិធានការសុខភាពសាធារណៈ និងសង្គម នៅក្នុងពេលដែលមានការបើកប្រទេសកម្ពុជាឡើងវិញ ជាពិសេសក្នុងចំណោមក្រុមប្រជាពលរដ្ឋមួយចំនួន និងនៅតាមកន្លែងផ្សេងៗ ដូចជាការមិនអនុវត្ត ៣ ការពារ និង ៣ កុំ ដូចជានៅតាមទីផ្សារ ផ្សារក្នុងសហគមន៍ មធ្យោបាយដឹកជញ្ជូនសាធារណៈ កន្លែងធ្វើការ និងការជួបជុំផ្សេងៗ។ លទ្ធផលស្រាវជ្រាវបានបង្ហាញថា ប្រជាពលរដ្ឋកម្ពុជា៦៣% មានជំនឿយ៉ាងមុតមាំថា ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន អនុវត្តវិធានការការពារ ប៉ុន្តែមានការខ្វះចន្លោះក្នុងការបង្ហាញពីវិធានាការការពារផ្ទាល់ខ្លួន និងការអង្កេតមើលពីអ្នកដទៃ។ ទោះជាយ៉ាងណាក៏ដោយ វាមានការធ្លាក់ចុះចំពោះការអនុវត្តវិធានការ ការពារ ជាពិសេសនៅក្នុងអំឡុងពេលនៃការបើកប្រទេសឡើងវិញ។
- មនុស្សចាស់ និងប្រជាពលរដ្ឋដែលរស់នៅតាមជនបទ និងតំបន់ដាច់ស្រយាលខ្វះព័ត៌មានអំពីវ៉ាក់សាំង និងវិធានការសុខភាពសាធារណៈ និងសង្គម។
- ប្រជាពលរដ្ឋដែលងាយរងគ្រោះមានការយល់ច្រឡំ ឬមិនបានទទួលព័ត៌មានគ្រប់គ្រាន់អំពីវ៉ាក់សាំង និង អំពីវិធានសុខភាពសាធារណៈ និងសង្គម។
- ប្រជាពលរដ្ឋចែករំលែកព័ត៌មានមិនបានត្រឹមត្រូវទាក់ទងនឹងវ៉ាក់សាំង និងវិធានការសុខភាពសាធារណៈ និងសង្គម។
- អជ្ញាធរមូលដ្ឋានមិនទាន់ទទួលបានការពង្រឹងសមត្ថភាព ដើម្បីផ្សព្វផ្សាយសារអប់រំស្តីអំពីវិធានការសុខភាពសាធារណៈនិងសង្គម និងខ្វះការគាំទ្រលើការងារអភិបាលកិច្ចចំពោះពួកគាត់ ដើម្បីឲ្យពួកគាត់អនុវត្តសកម្មភាពនៅក្នុងសហគមន៍ តាមដានបញ្ហាសុខភាព និងពាក្យចចាមអារ៉ាមនៅក្នុងសហគមន៍របស់ពួកគាត់។
- មានសារអប់រំច្រើន ឬក៏វិធីផ្សព្វផ្សាយផ្សេងៗគ្នានៅក្នុងសហគមន៍ និងតាមបណ្តាខេត្ត និងតំបន់មួយចំនួន។
- ការជឿជាក់លើវ៉ាក់សាំងនាំឲ្យមានការធ្លាក់ចុះចំពោះការអនុវត្តវិធានការសុខភាពសាធារណៈ និងសង្គម។

# គោលដៅ
# យុទ្ធសាស្ត្រ

# ២. គោលដៅយុទ្ធសាស្ត្រ

គោលបំណងយុទ្ធសាស្ត្រផែនការប្រាស្រ័យទាក់ទងរួមមាន៖



១. លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីហានិភ័យ ដោយមានការពន្យល់ឲ្យប្រជាពលរដ្ឋយល់ថា មេរោគកូរូណាគឺកំពុងតែរាតត្បាតនៅក្នុងប្រទេសកម្ពុជា និងសង្គមទាំងមូល ដែលតម្រូវឲ្យពួកគាត់មានការអនុវត្តនូវវិធានការសុខភាពសារធារណៈនិងសង្គម ដើម្បីមានសុវត្ថិភាពចំពោះការបើកប្រទេសឡើងវិញ និងដើម្បីធានាថាប្រព័ន្ធសុខាភិបាលបានត្រៀមរួចជាស្រេចក្នុងការគ្រប់គ្រងជំងឺ ប្រសិនបើមានការផ្ទុះជំងឺឡើងវិញជាថ្មី។



២. រក្សា និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន (ប្រជាពលរដ្ឋទូទៅ អ្នកធ្វើសេចក្តីសម្រេចចិត្ត បុគ្គលិកថែទាំសុខភាព ។ល។) អំពីលទ្ធភាពក្នុងការអនុវត្ត វិធានការហាមឃាត់ការធ្វើដំណើរ និងការបិទខ្ទប់ “ Blanket Measures ” ប្រសិនជាប្រព័ន្ធសុខាភិបាលជួបប្រទះចំពោះការរាតត្បាតជំមួយ ដែលមិនអាចគ្រប់គ្រងទាន់សភាពការបាន។



៣. ពង្រឹងការចូលរួមរបស់សហគមន៍ដើម្បីធានាលើការអនុវត្តវិធានការសុខភាពសាធារណៈនិងសង្គម។

៤. ពង្រឹងការចូលរួមរបស់សហគមន៍ដើម្បីរក្សាភាពជឿជាក់ ចំពោះវិធានការសុខភាពសាធារណៈនិងសង្គម និងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និងការជំនះបាននូវការផ្តល់ពត៌មានដែលមិនបានត្រឹមត្រូវ និងពាក្យចចាមអារ៉ាមនានា។

# ពិធីសាស្ត្រអនុវត្ត
# យុទ្ធសាស្ត្រ
# សំខាន់ៗ

# ៣. វិធីសាស្ត្រអនុវត្តយុទ្ធសាស្ត្រសំខាន់ៗ

ដើម្បីសម្រេចបាននូវគោលបំណងនៃការបើកប្រទេសឡើងវិញ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាផ្តោតលើអាទិភាព ចំនួន ៤ រួមមាន៖

*១. លើកកម្ពស់ការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូបក្នុងការរស់នៅ និងការចូលរួមក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ចតាមគន្លងប្រក្រតីភាពថ្មី។*

*២.ពង្រឹងប្រព័ន្ធសុខាភិបាលដោយផ្តោតជាចម្បងលើសមត្ថភាពនៃការត្រៀមបម្រុង និងការឆ្លើយតបទាន់ពេលប្រកបដោយប្រសិទ្ធភាព ក្នុងការបង្ការ និងការគ្រប់គ្រងជំងឺកូវីដ-១៩ និងលើសមត្ថភាពនៃការផ្តល់សេវាព្យាបាល និងថែទាំ ជាពិសេសការស្វះស្វែងរកឱសថ វិធីសាស្ត្រនិងបច្ចេកទេសវេជ្ជសាស្ត្រថ្មី ដែលធានាដល់ការព្យាបាលប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាពលរដ្ឋ និងរក្សាឲ្យបាននូវនិរន្តរភាពនៃដំណើរការនៃសកម្មភាពសង្គម-សេដ្ឋកិច្ច។*

*៣. បើកដំណើរការឡើងវិញនូវសកម្មភាពសង្គម-សេដ្ឋកិច្ច ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ដោយភ្ជាប់ជាមួយនឹងវិធានការសុវត្ថិភាព វិធានការសុខាភិបាល និងវិធានការរដ្ឋបាល សមស្របតាមកម្រិតហានិភ័យនៅតាមតំបន់ ទីតាំង និងតាមប្រភេទនៃសកម្មភាពសង្គម-សេដ្ឋកិច្ចនីមួយៗ។*

*៤. តាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយជាប្រចាំ នូវស្ថានភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងផលប៉ះពាល់លើសុខភាពសាធារណៈ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាពសង្គម-សេដ្ឋកិច្ច នៅតាមតំបន់ និងទូទាំងប្រទេស។*

ការបើកឡើងវិញនៃសង្គមកម្ពុជានៅក្នុងបរិបទនៃជំងឺកូវីដ-១៩ នឹងបង្កើនឲ្យមានការទំនាក់ទំនងយ៉ាងសកម្មនៅក្នុងសង្គម ព្រមទាំងមានការគិតរំពឹងទុកថា នឹងមានផលជាវិជ្ជមានចំពោះសេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី ការបើកឡើងវិញនេះអាចបង្កើនឲ្យមានហានិភ័យនៃការផ្ទុះឡើងវិញចំពោះការឆ្លងនៃជំងឺ ប្រសិនបើពុំមានការរៀបចំជាប្រព័ន្ធឲ្យហើយបុគ្គលម្នាក់ៗមិនបានអនុវត្តវិធានការសុខាភិបាលនិងសង្គមឲ្យបានត្រឹមត្រូវ។ ហេតុដូចនេះ ដើម្បីសម្រេចបានគោលបំណងទាំងអស់នេះ ផែនការប្រាស្រ័យទាក់ទងនេះចាំបាច់ត្រូវតែផ្តោតលើវិធីសាស្ត្រ (ការអនុវត្តគ្រប់យ៉ាង) និងការចាក់វ៉ាក់សាំងកូវីដ-១៩។



## ៣.១ យុទ្ធសាស្ត្រនៃបទអន្តរាគមន៍សំខាន់ៗ

យុទ្ធសាស្ត្រអន្តរាគមន៍សំខាន់ៗ គឺត្រូវមានផែនការជាក់លាក់ក្នុងចែករំលែកព័ត៌មានដល់មនុស្សគ្រប់រូប ដើម្បីការពារខ្លួនគេនិងមនុស្សជាទីស្រឡាញ់របស់គេដោយការចាក់វ៉ាក់សាំង និងអនុវត្តវិធានការការពារ តាមរយៈការបង្កើនភាពស្មោះត្រង់និងបើកចំហ មានតម្លាភាព និងការប្រាស្រ័យទាក់ទងទាន់ពេលវេលា។ វាមានសារៈសំខាន់ដើម្បីបន្តផ្តល់សារអប់រំ អំពីហានិភ័យនៃជំងឺផ្សេងៗ ជាពិសេសដល់ក្រុមមនុស្សដែលងាយរងគ្រោះ សារៈសំខាន់នៃការចាក់សាំងនៅពេលដែលដល់វេនដែលត្រូវចាក់ ដោយការបង្ហាញសុវត្ថិភាព និងប្រសិទ្ធភាពនៃវ៉ាក់សាំង រួមជាមួយនឹងវិធានការការពារផ្សេងៗទៀត។

- បន្តការចែករំលែកការអប់រំផ្សព្វផ្សាយ (អនុវត្តគ្រប់យ៉ាង) តាមរយៈបណ្តាញព័ត៌មានសាធារណៈ និងបណ្តាញសង្គម និងបណ្តាញនានារបស់ដៃគូ ដើម្បីលើកកម្ពស់ការប្រព្រឹត្តិផ្នែកសុខភាព និងកាត់បន្ថយលទ្ធភាពនៃការឆ្លងថ្មីនៅក្នុងសហគមន៍ ក៏ដូចជាជួយរក្សាសមត្ថភាពរចនាសម្ព័ន្ធសុខាភិបាល។ រៀបចំឲ្យមានការពង្រឹងសមត្ថភាពបុគ្គលិកសុខាភិបាល រដ្ឋអំណាចមូលដ្ឋាន ក្រុមទ្រទ្រង់សុខភាពភូមិ និងអ្នកដែលមានឥទ្ធិពលនៅក្នុងមូលដ្ឋាន ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេ ក្នុងការកំណត់បញ្ហា និងដំណោះស្រាយនានាដែលមាននៅក្នុងមូលដ្ឋាន និងធ្វើការផ្សព្វផ្សាយវិធានការសុខភាពសាធារណៈ និងសង្គម នៅក្នុងបរិបទមូលដ្ឋានរបស់គេ។
- បង្កើននិងពង្រឹងសមត្ថភាពរចនាសម្ព័ន្ធសហគមន៍ដែលមានស្រាប់ តាមរយៈការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល អ្នកអនុវត្តសកម្មភាពក្នុងសហគមន៍ និងអជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់សារអប់រំឲ្យបានសកម្ម និងដឹកនាំការពិភាក្សាក្នុងសហគមន៍ជាមួយនឹងក្រុមមនុស្សនានាដែលមានហានិភ័យ ដើម្បីបង្ហាញមូលហេតុដែលមានបានអនុវត្តតាមវិធានការសុខាភិបាលនិងសង្គម រួមមានភាពហត់នឿយ កង្វះខាតព័ត៌មានអំពីហានិភ័យ និងការមានភាពសុទិដ្ឋិនិយមអំពីវ៉ាក់សាំង។
- ផ្សព្វផ្សាយសារអប់រំតាមរយៈវេទិការប្រាស្រ័យទាក់ទង និងព្រឹត្តិការណ៍នានា ដោយមានកិច្ចសហការជាមួយអ្នកពាក់ព័ន្ធនិងដៃគូ និងការបង្កើតឲ្យមានការចូលរួមនៃប្រជាជនទូទៅ និងសហគមន៍ ដើម្បីចែករំលែកសារអប់រំ ពីប្រភពដែលមានការការជឿជាក់ស្តីពីវិធានការ ការពារកូវីដ-១៩ និងការចាក់វ៉ាក់សាំង។

# ដៃគូ

# គូលប្ឋឃអនុខគ្គ

## ៤. ដៃគូចូលរួមអនុវត្ត

ផែនការយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនេះ គឺជាគន្លឹះយ៉ាងសំខាន់ ដើម្បីលើកកម្ពស់វិធានការសុខភាពសាធារណៈ និងសង្គម អាស្រ័យហេតុនេះ ដៃគូដែលមានការពាក់ព័ន្ធនឹងត្រូវបានឲ្យចូលរួមដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ។ ដៃគូអនុវត្តទាំងអស់នោះរួមមាន៖

- ស្ថាប័នបច្ចេកទេសដែលមានការពាក់ព័ន្ធ និងអជ្ញាធរនៅថ្នាក់ក្រោមជាតិ ដូចជា មន្ទីរជំនាញក្នុងខេត្ត និងមន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ ដែលស្ថិតនៅក្រោមក្រសួងសុខាភិបាល
- ក្រសួងដែលពាក់ព័ន្ធនានា
- វិស័យឯកជន
- ដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ
- អង្គការសង្គមស៊ីវិល និងអង្គការនានាដែលបានបង្កើតនិងអនុវត្តសកម្មភាពនៅក្នុងសហគមន៍
- ព្រឹទ្ធាចារ្យ (ព្រះសង្ឃ អាចារ្យ និងអ្នកដែលមានឥទ្ធិពលក្នុងភូមិ) និងសាលារៀន
- ការផ្សព្វផ្សាយព័ត៌មានតាមបណ្តាញទំនាក់ទំនងសង្គម វិទ្យុ ទូរទស្ស និងបណ្តាញផ្សព្វផ្សាយនានា
- ក្រុមការងារទំនាក់ទំនងហានិភ័យ និងការចូលរួមរបស់សហគមន៍។



# ការអប់រំ និង
# វិធីសាស្ត្រផ្សព្វផ្សាយ

# ៥. សារអប់រំ និងវិធីសាស្រ្តផ្សព្វផ្សាយ

សារអប់រំអាចធ្វើការផ្លាស់ប្តូរ ឬកែប្រែទៅតាមប្រធានបទ ប្រភេទ និងបរិបទនៅក្នុងមូលដ្ឋាន តាមរយៈការកែប្រែពាក្យពេចន៍ ឬក៏ការបង្រួញអាស្រ័យទៅលើតម្រូវការជាក់ស្តែង។ នៅពេលដែលយើងនិយាយអំពីវ៉ាក់សាំងកូវីដ-១៩ វាចាំបាច់បំផុតដើម្បីបញ្ជាក់បង្ហាញអំពីសារៈសំខាន់ចំពោះការអនុវត្តវិធានការ ការពារកូវីដ-១៩ ទោះជាបានចាក់វ៉ាក់សាំងរួចហើយក៏ដោយ។

## ៥.១ វិធានការសុខភាពសាធារណៈនិងសង្គម

| សារអប់រំ | មធ្យោបាយផ្សព្វផ្សាយ |
|---|---|
| • ពាក់ម៉ាស់<br>• ពាក់ម៉ាស់ឲ្យបានត្រឹមត្រូវ គ្របច្រមុះ មាត់ និងចង្កា | មានមធ្យោបាយផ្សព្វផ្សាយច្រើនបែប ដែលអាចជ្រើសរើសនៅក្នុងឧបសម្ព័ន្ធ ជំពូកទី៧។ សារអប់រំ និងមធ្យោបាយផ្សព្វផ្សាយអាចជ្រើសរើស និងប្រើប្រាស់ទៅតាមបរិបទដែលប្រជាពលរដ្ឋកំពុងរស់នៅ និងទៅតាមប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ |
| • រក្សាគម្លាតបុគ្គល យ៉ាងហោចណាស់ចម្ងាយ ១.៥ ម៉ែត្រពីគ្នា | |
| • លាងសម្អាតដៃជានិច្ចជាមួយទឹក និងសាប៊ូ ឬអាកុលជែល<br>Clean hands with soap and water or alcohol-based rub | |
| • ជៀសវាងកន្លែងដែលមានមនុស្សច្រើន<br>Avoid crowded place | |
| • ជៀសវាងការជួបជុំនៅជិតគ្នា<br>Avoid close-contact settings | |
| • ជៀសវាងកន្លែងបិទជិត<br>Avoid confined spaces | |
| • ស្នាក់នៅផ្ទះប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលខ្លួន<br>Stay at home if feeling unwell | |
| • ខ្ទប់មាត់ ច្រមុះជាមួយនឹងកែងដៃ ឬប្រើក្រដាស ពេលអ្នកក្អក ឬ កណ្តាស់<br>Cover your mouth and nose with a bent elbow or tissue when you cough or sneeze. | |
| • បើអាច បើកបង្អួច ដើម្បីឲ្យមានខ្យល់ចេញចូលច្រើន<br>When possible, open a window to increase the amount of natural ventilation in indoor settings | |

# ៥.២ សារអប់រំពីការចាក់វ៉ាក់សាំង

| **សារអប់រំ**<br>មានសារអប់រំជាច្រើនដែលអាចជ្រើសរើសនៅក្នុងឧបសម្ព័ន្ធ | **មធ្យោបាយផ្សព្វផ្សាយ**<br>មានមធ្យោបាយផ្សព្វផ្សាយច្រើនបែប ដែលអាចជ្រើសរើសនៅក្នុងឧបសម្ព័ន្ធ ជំពូកទី៧។ សារអប់រំ និងមធ្យោបាយផ្សព្វផ្សាយអាចជ្រើសរើស និងប្រើប្រាស់ទៅតាមបរិបទដែលប្រជាពលរដ្ឋកំពុងរស់នៅ និងទៅតាមប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ |
|---|---|
| • សូមទៅចាក់វ៉ាក់សាំងកូវីដ-១៩ ឲ្យបានឆាប់តាមដែលអាចធ្វើបាន នៅពេលដល់វេនអ្នក។<br>Get vaccinated as soon as it’s your turn.<br><br>• ចាក់វ៉ាក់សាំងសង្គ្រោះអាយុជីវិតរបស់អ្នក<br>Getting vaccinated could save your life.<br><br>• វ៉ាក់សាំងកូវីដ-១៩ ការពារអ្នកពីការឈឺធ្ងន់ សម្រាកពេទ្យ ឬស្លាប់បាន<br>COVID-19 vaccines provide strong protection against serious illness, hospitalization and death. | |
| • ទោះជាអ្នកចាក់វ៉ាក់សាំងកូវីដ-១៩ រួចក៏ដោយ បន្តអនុវត្តវិធានការការពាររួមមាន:<br>Even if you’re vaccinated, continue to practice protective measures including,<br>1. រក្សាគម្លាតសុវត្ថិភាពបុគ្គល<br>physical distancing,<br>2. ពាក់ម៉ាស់<br>mask wearing,<br>3. ខ្ទប់មាត់ពេលក្អកឬកណ្តាស់<br>covering coughs and sneezes,<br>4. លាងសម្អាតដៃជាមួយសាប៊ូ<br>cleaning hands,<br>5. បើកបង្អួច<br>and opening windows, when possible, etc. | |
| • អ្នកអាចចាក់វ៉ាក់សាំងកូវីដ-១៩ បាន ប្រសិនបើអ្នកកំពុងមានផ្ទៃពោះ ឬក៏អ្នកមានផែនការមានផ្ទៃពោះ<br>"You can get a COVID-19 vaccine if you are pregnant or planning to get pregnant" | |
| • ចូរពិគ្រោះជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាព អំពីការទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩<br>“Talk to your healthcare provider about getting the COVID-19 vaccine” | |
| • អ្នកអាចវ៉ាក់សាំងកូវីដ-១៩ បាន នៅពេលអ្នកកំពុងបំបៅដោះកូន | |

| | |
|---|---|
| "You can get a COVID-19 vaccine when you are breastfeeding" | |
| • វាមានសុវត្ថិភាពចំពោះអ្នកនិងកូនរបស់អ្នក និងអាចការពារកូនរបស់អ្នកតាមរយៈអង់ទីគរដែលមាននៅក្នុងទឹកដោះ។<br>It is safe for you and your baby and may protect your baby through antibodies in the breast milk. | |
| • អ្នកមិនគួរបញ្ឈប់ការបំបៅដោះកូន ដោយសារតែអ្នកបានចាក់វ៉ាក់សាំងកូវីដ-១៩នោះទេ។<br>"You shouldn't stop breastfeeding because of the COVID-19 vaccination" | |



# ៦. ផែនការប្រាស្រ័យទាក់ទង

| គោលបំណង | វិធីសាស្ត្រ អនុវត្តយុទ្ធសាស្ត្រសំខាន់ៗ | សកម្មភាពសំខាន់ៗ | ដៃគូអនុវត្តសកម្មភាព | សារអប់រំ និងវិធីសាស្ត្រផ្សព្វផ្សាយ | ការត្រួតពិនិត្យ និងវាយតម្លៃ |
|---|---|---|---|---|---|
| ១. លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីហានិភ័យ ដោយមានការពន្យល់ឲ្យប្រជាពលរដ្ឋយល់ថា មេរោគកូរ៉ូណាគឺកំពុងតែរាតត្បាតនៅក្នុងប្រទេសកម្ពុជា និងសង្គមទាំងមូល ដែលតម្រូវឲ្យពួកគាត់មានការអនុវត្តនូវវិធានការសុខភាពសារធារណៈនិងសង្គម ដើម្បីមានសុវត្ថិភាពចំពោះការបើកប្រទេសឡើងវិញ និងដើម្បីធានាថាប្រព័ន្ធសុខាភិបាលបានត្រៀមរួចជាស្រេចក្នុងការគ្រប់គ្រងជំងឺប្រសិនបើមានការផ្ទុះជំងឺឡើងវិញជាថ្មី។ | ១. បន្តការចែករំលែកការអប់រំផ្សព្វ ផ្សាយ (អនុវត្តគ្រប់យ៉ាង) តាមរយៈបណ្តាញព័ត៌មានសាធារណៈ និងបណ្តាញសង្គម និងបណ្តាញនានារបស់ដៃគូ ដើម្បីលើកកម្ពស់ការប្រព្រឹត្តិផ្នែកសុខភាព និងកាត់បន្ថយលទ្ធភាពនៃការឆ្លងថ្មីនៅក្នុងសហគមន៍ ក៏ដូចជាជួយរក្សាសមត្ថភាពរចនាសម្ព័ន្ធសុខាភិបាល។ រៀបចំឲ្យមានការពង្រឹងសមត្ថភាពបុគ្គលិកសុខាភិបាល រដ្ឋអំណាចមូលដ្ឋាន អ្នកស្ម័គ្រចិត្តភូមិ និងអ្នកដែលមានឥទ្ធិពលនៅក្នុងមូលដ្ឋាន ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេ ក្នុងការកំណត់បញ្ហា និងតំណោះស្រាយ | • ពង្រឹងប្រព័ន្ធនានាដែលមានស្រាប់ តាមរយៈយន្តការផ្សេងៗ<br>• រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីពង្រឹងសមត្ថភាពបុគ្គលិកសុខាភិបាល និងបណ្តាញការងារផ្សេងៗ រួមទាំងបណ្តាញការងារដែលមានស្រាប់ (សង្គមស៊ីវិល និងបណ្តាញសហគមន៍ ដូចជាអ្នកទ្រទ្រង់សុខភាពភូមិ និងអ្នកស្ម័គ្រចិត្ត<br>• ការផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នានា (តាមរយៈវេទិការពិភាក្សា តាមរយៈទូរទស្សន៍និងវិទ្យុ ។ល។) | • ស្ថាប័នបច្ចេកទេសដែលមានការពាក់ព័ន្ធ និងអជ្ញាធរនៅថ្នាក់ក្រោមជាតិ ដូចជា មន្ទីរជំនាញក្នុងខេត្ត និងមន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព អ្នកស្ម័គ្រចិត្តទ្រទ្រង់សុខភាពភូមិ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ ដែលស្ថិតនៅក្រោមក្រសួងសុខាភិបាល<br>• ក្រសួងដែលពាក់ព័ន្ធនានា<br>• វិស័យឯកជន<br>• ដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ<br>• អង្គការសង្គមស៊ីវិល និងអង្គការនានាដែលបានបង្កើតនិងអនុវត្តសកម្មភាពនៅក្នុងសហគមន៍ | មានមធ្យោបាយផ្សព្វផ្សាយច្រើនបែបដែលអាចជ្រើសរើសនៅក្នុងឧបសម្ព័ន្ធជំពូកទី៧។ សារអប់រំ និងមធ្យោបាយផ្សព្វផ្សាយអាចជ្រើសរើស និងប្រើប្រាស់ទៅតាមបរិបទដែលប្រជាពលរដ្ឋកំពុងរស់នៅ និងទៅតាមប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ | • កិច្ចប្រជុំ<br>• របាយការណ៍វឌ្ឍនភាព<br>• ការប្រមូលទិន្នន័យអង្កេត<br>• ការស្រាវជ្រាវ/អង្កេតនៅតាមសហគមន៍<br>• យន្តការព័ត៌មានត្រឡប់ ដូចជាការទៅសួរសុខទុក្ខនៅតាមផ្ទះ ការសាកសួរតាមរយៈក្រុមពិភាក្សា ការប្រមូលព័ត៌មានតាមរយៈទូរសព្ទ័ និងព័ត៌មានសុខាភិបាល |

| | | | | | |
|---|---|---|---|---|---|
| ២. រក្សានិងលើកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន (ប្រជាពលរដ្ឋទូទៅ អ្នកធ្វើសេចក្តីសម្រេចចិត្ត បុគ្គលិកថែទាំសុខភាព ។ល។) អំពីលទ្ធភាពក្នុងការអនុវត្ត វិធានការហាមឃាត់ការធ្វើដំណើរ និងការបិទខ្ទប់ "Blanket Measures " ប្រសិនជាប្រព័ន្ធសុខាភិបាលជួបប្រទះចំពោះការរាតត្បាតធំមួយដែលមិនអាចគ្រប់គ្រងទាន់សភាពការបាន។<br>៣. ពង្រឹងការចូលរួមរបស់សហគមន៍ដើម្បីធានាលើការអនុវត្តវិធានការសុខភាពសាធារណៈនិងសង្គម។<br>៤. ពង្រឹងការចូលរួមរបស់សហគមន៍ដើម្បីរក្សាភាពជឿជាក់ ចំពោះវិធានការសុខភាពសាធារណៈ និង សង្គម និង | នានាដែលមាននៅក្នុងមូលដ្ឋាន និងធ្វើការផ្សព្វផ្សាយវិធានការសុខភាពសាធារណៈ និងសង្គម នៅក្នុងបរិបទមូលដ្ឋានរបស់គេ។<br>២. បង្កើននិងពង្រឹងសមត្ថភាពរចនាសម្ព័ន្ធសហគមន៍ដែលមានស្រាប់ តាមតយៈការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល អ្នកអនុវត្តសកម្មភាពក្នុងសហគមន៍ និងអជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់សារអប់រំឲ្យបានសកម្ម និងដឹកនាំការពិភាក្សាក្នុងសហគមន៍ជាមួយនឹងក្រុមមនុស្សនានាដែលមានហានិភ័យ ដើម្បីបង្ហាញមូលហេតុដែលមានបានអនុវត្តតាមវិធានការសុខាភិបាលនិងសង្គម រួមមានភាពហត់នឿយ កង្វះខាតព័ត៌មានអំពីហានិភ័យ និង ការមានភាពសុទិដ្ឋិនិយមអំពីវ៉ាក់សាំង។<br>៣. ផ្សព្វផ្សាយសារអប់រំតាមរយៈវេទិកាប្រាស្រ័យទាក់ទង និងព្រឹត្តិការណ៍នានា ដោយមានកិច្ច | • បោះពុម្ពសម្ភារៈអប់រំ (ផ្ទាំងរូបភាព ប័ណ្ណសន្លឹកបត់ ខិត្តប័ណ្ណ និងបដា ។ល។)<br>• ការគាំពារមេតិ (ការចូលរួមក្នុងសកម្មភាពផ្សេងៗ និងសន្ទរកថារបស់ថ្នាក់ដឹកនាំ)<br>• បង្កើតវេទិការ និងមធ្យោបាយផ្សព្វផ្សាយផ្សេងៗ | • ព្រឹទ្ធចារ្យ (ព្រះសង្ឃ អាចារ្យ និងអ្នកដែលមានឥទ្ធិពលក្នុងភូមិ) និងសាលារៀន<br>• ការផ្សព្វផ្សាយព័ត៌មានតាមទំនាក់ទំនងសង្គម វិទ្យុ ទូរទស្សន៍ និងបណ្តាញផ្សព្វផ្សាយនានា<br>• ក្រុមការងារទំនាក់ទំនងហានិភ័យ និងការចូលរួមរបស់សហគមន៍ | | |

| | | | | | |
|---|---|---|---|---|---|
| យុទ្ធនាការចាក់ថ្នាំវ៉ាក់សាំងកូវីដ-១៩ និងការជំនះបាននូវការផ្តល់ព័ត៌មានដែលមិនបានត្រឹមត្រូវ និងពាក្យចចាមអារ៉ាមនានា។ | សហការជាមួយអ្នកពាក់ព័ន្ធនិងដៃគូ និងការបង្កើតឲ្យមានការចូលរួមនៃប្រជាជនទូទៅ និងសហគមន៍ ដើម្បីចែករំលែកសារអប់រំ ពីប្រភពដែលមានការការជឿជាក់ស្តីពីវិធានការការពារកូវីដ-១៩ និងការចាក់វ៉ាក់សាំង។ | | | | |



# ឧបសម្ព័ន្ធ

# ៧. ឧបសម្ព័ន្ធ

ខាងក្រោមនេះផ្តល់ព័ត៌មានបន្ថែមសម្រាប់ជ្រើសរើសសារអប់រំដែលទាក់ទងទៅនឹងវិធានការ ការពារកូវីដ-១៩ និងវ៉ាក់សាំង និងអំពីមធ្យោបាយផ្សព្វផ្សាយព័ត៌មានអប់រំ។

## សារអប់រំសំខាន់ៗ និងអត្ថបទអំពីវិធានការ ការពារកូវីដ-១៩

1. Euro article: What are public health and social health measures and why are they still needed at this stage in the COVID-19 pandemic?
2. Coronavirus disease (COVID-19): Variants of SARS-COV-2: https://www.who.int/emergencies/diseases/novel-coronavirus-2019/question-and-answers-hub/q-a-detail/coronavirus-disease-(covid-19)-variants-of-sars-cov-2

## សម្ភារអប់រំតាមរយៈព័ត៌មានសង្គម

3. Do it all animation: 'Do it all' content: https://who.canto.global/b/UJ4JK
4. COVID-19 transmission animation: https://who.canto.global/b/GD45O
5. School safety: https://who.canto.global/b/IPJVV
6. End-year tiles: (to be available soon)
7. Safe travel: (to be available soon)
8. Masks: How to properly fit a mask: https://who.canto.global/b/RUCF9
9. Hand hygiene: https://who.canto.global/b/P6UU8
10. Delta variant: https://who.canto.global/b/HS2QR

## សម្ភារអប់រំអំពីវ៉ាក់សាំង

11. Vaccine tiles from HQ: https://who.canto.global/b/RHD4R
12. Be a hero, do it all: https://who.canto.global/b/GH5HC
13. Vaccine, do it all: https://who.canto.global/b/I6N2D
14. Vaccines & pregnancy
    - WPRO tiles: https://who.canto.global/b/O282A
    - Text tiles: https://who.canto.global/b/GU4RE
    - Short videos: https://who.canto.global/b/ILMCB